# ទំនុកដំកើង ១៣០

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

ប្រពៃណីបានចុះបញ្ជី «ទំនុកដំកើងវិប្បដិសារៈ» ចំនួនប្រាំពីរ (ទំនុកដំកើង ៦, ៣២, ៣៨, ៥១, ១០២, ១៣០, ១៤៣)។ សេចក្តីសុច្ចរឹតគឺជាផ្ទៃរឿងសំខាន់មួយនៅក្នុងទំនុកដំកើង ១២៩-១៣១។ ទំនុកដំកើង ១២៩ ប្រកាសថា ប្រសិនបើព្រះដ៏សុច្ចរឹតការពាររាស្ត្ររបស់ទ្រង់ នោះគ្មានខ្មាំងសត្រូវណាអាចមកយកឈ្នះលើពួកគេបានឡើយ។ ទោះយ៉ាងណា ទំនុកដំកើង ១៣០ បង្ហាញអំពីបញ្ហាដែលការវិនិច្ឆ័យដ៏សុច្ចរឹតរបស់ព្រះអាចធ្លាក់មកលើរាស្ត្ររបស់ទ្រង់ផ្ទាល់។ ពាក្យចាប់ផ្តើមរបស់ទំនុកដំកើងនេះថ្លែងថា អ្នកនិពន្ធអំពាវនាវ *ពីទីជំរៅ* ដែលបង្ហាញថាគាត់ស្ថិតនៅក្នុងស្ថានភាពអស់សង្ឃឹម ដែលយើងនឹងមើលឃើញថាវាមកដោយសារតែអំពើបាបរបស់គាត់ផ្ទាល់។ គាត់មិនអាចសង្គ្រោះខ្លួនឯងចេញពីបញ្ហានេះ និងចេញពីលទ្ធផលនៃអំពើបាបផ្ទាល់ខ្លួនរបស់គាត់បានទេ។ ទោះយ៉ាងណា ពេញក្នុងទំនុកដំកើងនេះមានការឡើងត្រង់ឆ្ពោះទៅឯការធានាដែលគាត់ឃើញថាព្រះអត់ទោស (ខ. ៣-៤) ហើយដូច្នេះការនេះនាំទៅដល់ការរង់ចាំសេចក្តីប្រោសលោះដែលមកពីព្រះ (ខ. ៥-៦) ហើយនៅទីបំផុតមានការលើកទឹកចិត្តសំរាប់មនុស្សជាច្រើនឲ្យដាក់សេចក្តីសង្ឃឹមរបស់ពួកគេទៅលើព្រះយ៉ាវេដូចដែលអ្នកនិពន្ធបានធ្វើផងដែរ (ខ. ៧-៨)។

**ខ. ១, ២** *ជំរៅ* គឺជារូបភាពមួយអំពីសេចក្តីអស់សង្ឃឹម (សូមមើលទំនុកដំកើង ៦៩:១-២..., ១៤-១៥...)។ នៅពេលយើងស្ថិតក្នុងស្ថានភាពបែបដូច្នេះ យើងដឹងថាយើងមិនអាចសង្គ្រោះខ្លួនឯងយើងបានទេ ហើយការនេះបណ្តាលឲ្យយើងទុកចិត្តលើព្រះជាជំនួយវិញ។ គាត់សុំសេចក្តីមេត្តាករុណា ដែលនេះបង្ហាញថាគាត់ដឹងថាគាត់មិនសមទទួលសេចក្តីប្រោសលោះពីព្រះទេ ប៉ុន្តែគាត់អាចទទួលវាបានដោយឈរលើមូលដ្ឋាននៃសេចក្តីល្អរបស់ព្រះតែប៉ុណ្ណោះ។ សេចក្តីអង្វរឲ្យព្រះស្តាប់បង្ហាញថាព្រះមិនចាំបាច់ស្តាប់និងឆ្លើយតបសេចក្តីអធិស្ឋានរបស់យើងនោះទេ ដូច្នេះសេចក្តីអធិស្ឋានចាប់ផ្តើមដោយការសូមថាព្រះនឹងស្តាប់និងឆ្លើយតប។ សេចក្តីសំណូមនេះគឺជាការចាប់ផ្តើមញឹកញាប់មួយនៃសេចក្តីអធិស្ឋាននៅក្នុងទំនុកដំកើង (ឧទាហរណ៍ៈ ទំនុកដំកើង ៥:១, ១៧:១, ៦, ២៨:១, ៣១:២, ៧១:២, ៨៨:២, ១០២:២)។

**ខ. ៣, ៤** ខទាំងនេះសំដែងអំពីបញ្ហារបស់គាត់ដែលខុសពីបញ្ហាជំងឺ ជំងឺនឹកផ្ទះសំបែង ឬការបៀតបៀនដែលមាននៅក្នុងទំនុកដំកើងខ្លះផ្សេងទៀត (ឧទាហរណ៍ៈ ទំនុកដំកើង ៦, ៤២, ៦៩, ១២៩...ល)។ នៅទីនេះបញ្ហាគឺជាទោសកំហុសរបស់គាត់ផ្ទាល់។ ខនេះបញ្ជាក់អំពីសេចក្តីពិតមួយដែលសំខាន់ណាស់។ យើងមិនអាចគ្មានកំហុសនៅចំពោះព្រះបាននោះទេ។ ប្រសិនបើព្រះរក្សាទុកកំណត់ត្រានៃអំពើបាបយើងទាំងអស់ នោះយើងគ្មានសង្ឃឹមទេ។ មនុស្សល្ងីល្ងើគិតថាគាត់អាចឈរនៅចំពោះបល្ល័ង្កវិនិច្ឆ័យរបស់ព្រះបានដោយទុកចិត្តលើសេចក្តីល្អនិងអំពើល្អរបស់គាត់ផ្ទាល់។ សេចក្តីសង្ឃឹមតែមួយគឺនៅក្នុងសេចក្តីមេត្តាករុណាក្នុងការអត់ទោសរបស់ព្រះ ហើយអ្នកនិពន្ធដឹងថាព្រះយ៉ាវេពិតជាអត់ទោស។

**ខ. ៥, ៦** ដោយសារតែគាត់ដឹងថាព្រះអត់ទោស ការនេះនាំឲ្យគាត់រង់ចាំព្រះ។ សូមកត់សំគាល់ៈ ពាក្យហេព្រើដែលអ្នកនិពន្ធប្រើនៅទីនេះដែលបកប្រែថា *ទូលបង្គំ* ព្រះគម្ពីរខ្មែរបរិសុទ្ធបកប្រែថា *ខ្ញុំ* នៅក្នុងគ.ខ.ប គឺជាពាក្យហេព្រើដែលមានន័យត្រង់ «ព្រលឹង»។ អ្នកខ្លះបង្រៀនថា មនុស្សមានបីផ្នែក រូបកាយ ព្រលឹង និងវិញ្ញាណ ហើយផ្នែកនិមួយៗមានតួនាទីខុសៗពីគ្នា ហើយមានតែវិញ្ញាណទេដែលទាក់ទងនឹងព្រះ មិនមែនព្រលឹងនោះឡើយ។ ការបង្រៀនបែបនេះមិនត្រឹមត្រូវទេ។ គ្មានកន្លែងណានៅក្នុងព្រះគម្ពីរបង្រៀនបែបដូច្នេះទេ។ លើសពីនេះ នៅក្នុងទំនុកដំកើងជារឿយៗអ្នកនិពន្ធថ្លែងថាពួកគេថ្វាយបង្គំព្រះដោយ *ព្រលឹង* របស់ពួកគេ ពួកគេស្រលាញ់ព្រះដោយ *ព្រលឹង* របស់ពួកគេ ហើយក្នុងខនេះព្រលឹងរបស់គាត់រង់

ចាំព្រះ។

**ខ. ៧, ៨** ឥឡូវនេះ អ្នកនិពន្ធស្ថិតក្នុងស្ថានភាពដ៏ខុសគ្នាមួយពី «ជំរៅ» ដែលត្រូវបានលើកឡើងក្នុងខ.១។ បន្ទាប់ពីរង់ចាំព្រះបង្ហាញសេចក្តីមេត្តាករុណា ឥឡូវអ្នកចំរៀងប្រកាសទៅកាន់បណ្តាជនថា ពួកគេគួរតែដាក់សេចក្តីសង្ឃឹមរបស់ពួកគេទៅក្នុងព្រះអម្ចាស់ផងដែរ។ សេចក្តីសង្ឃឹមនោះគឺផ្អែកលើចរិតលក្ខណៈរបស់ព្រះដែលទ្រង់ពេញដោយសេចក្តីស្រលាញ់ដែលមិនចេះប្រែប្រួល។ ខ. ៨ ប្រាប់ថាព្រះប្រោសលោះអ៊ីស្រាអែលចេញពីអំពើបាបរបស់ខ្លួន ហើយព្រះគម្ពីរសញ្ញាថ្មីបង្រៀនថា ជាចុងក្រោយទ្រង់បានធ្វើការនេះតាមរយៈព្រះគ្រីស្ទ។

**ការអនុវត្ត**

ទំនុកដំកើងនេះបង្ហាញអំពីបញ្ហាដ៏ធំបំផុតរបស់យើង គឺព្រះជាព្រះបរិសុទ្ធហើយយើងគឺជាពួកមនុស្សមានបាប។ ខ. ៣ បង្ហាញយ៉ាងច្បាស់ថា គ្មានអ្នកណាសុច្ចរិតនៅចំពោះព្រះទេ។ សេចក្តីសង្ឃឹមតែមួយរបស់យើងគឺនៅក្នុងសេចក្តីអត់ទោសដែលមកពីព្រះនៅពេលដែលព្រះទាក់ទងជាមួយយើងដោយសេចក្តីមេត្តាករុណាជាជាងដោយសេចក្តីយុត្តិធម៌របស់ទ្រង់។ សូមសរសើរតម្កើងព្រះដែលទ្រង់គឺជាព្រះនៃសេចក្តីស្រលាញ់តែមួយព្រះអង្គដែលសព្វព្រះទ័យនឹងអត់ទោសការបះបោររបស់យើង (ខ. ៤, ៧)។ ដំណឹងល្អគឺជា*ដំណឹងល្អ*ពីព្រោះវាប្រកាសថា តាមរយៈព្រះជន្មរបស់ព្រះ យេស៊ូវ ការសុគត់នៅលើឈើឆ្កាងនិងការរស់ឡើងវិញរបស់ទ្រង់ យើងអាចទទួលសេចក្តីអត់ទោសពីព្រះបាន ដូច្នេះ យើងត្រូវតែដាក់ការទុកចិត្តរបស់យើងនក្នុងព្រះគ្រីស្ទ (រ៉ូម ៣:២១-៤.៨, ហេព្រើ ១០:១-១០)។

ទោះយ៉ាងណា អ្នកចំរៀងមិនគ្រាន់តែដាក់ការទុកចិត្តរបស់គាត់លើព្រះប៉ុណ្ណោះទេ ប៉ុន្តែក្នុងខ. ៧-៨ គាត់ថែមទាំងលើកទឹកចិត្តអ្នកផ្សេងឲ្យធ្វើដូច្នោះផងដែរ។ ការនេះគួរជាការឆ្លើយតបរបស់យើងទៅចំពោះដំណឹងល្អផងដែរ។ ប្រសិនបើយើងបានទទួលសេចក្តីអត់ទោសអំពើបាបរបស់យើងតាមរយៈព្រះគ្រីស្ទហើយដឹងសន្តិភាពនិងអំណរដែលមកតាមរយៈនេះ នោះយើងគួរតែចង់ឲ្យអ្នកដទៃទៀតបានទទួលសេចក្តីអត់ទោសនេះផងដែរ ហេតុដូច្នេះ យើងគួរតែប្រកាសឲ្យអ្នកដទៃបានទទួលជឿដំណឹងល្អផងដែរ។

**Bibliography**

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Keil, C. F., & Delitzsch, F. (1996). *Vol. 5*: *Commentary on the Old Testament*. Peabody, MA: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Spence-Jones H. D. M., Ed. (1909) *Psalms Vol. III.*. The Pulpit Commentary. London; New York: Funk & Wagnalls Company.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.